Public Disclosure Authorized

Public Disclosure Authorized

# ឯកសារព័ត៌មានគម្រោង

# ដំណាក់កាលវាយតំលៃ

របាយការណ៍លេខៈ AB2342

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងប្រយុទ្ធប្រឆាំងនឹងជម្ងឺផ្តាសាយបក្សី និងមនុស្ស និង<br>ត្រៀមលក្ខណៈទប់ទល់គ្រោះអាសន្ន |
| តំបន់ | អាស៊ីបូពា៌ និងប៉ាស៊ីហ្វិក |
| វិស័យ | សុខភាព (50%), ផលិតផលសត្វ (50%) |
| លេខសំគាល់គម្រោង | P100084 |
| អ្នកខ្ចី | រាជរដ្ឋាភិបាលកម្ពុជា |
| ទីភ្នាក់ងារអនុវត្តន៍ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក<br>ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា<br>សារអេឡិចត្រូនិកៈ maff@everyday.com.kh<br><br>ក្រសួងសុខភិបាល<br>ផ្លូវលេខៈ ១៥១-១៥៣ មហាវិថីកម្ពុជាក្រោម រាជធានីភ្នំពេញ កម្ពុជា<br>លេខអ៊ីម៉ែលៈ procure.peu@bigpond.com.kh<br><br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ផ្លូវលេខ ២៧៤ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ កម្ពុជា<br>លេខអ៊ីម៉ែលៈ vothana@everyday.com.kh |
| ផ្នែកបរិស្ថាន | [ ]A [x]B [ ]C [ ] E [ ] TBD (ត្រូវបានកំណត់) |
| កាលបរិច្ឆេទនៃការរៀបចំឯកសារពតិមានគម្រោង | ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៨ |
| កាលបរិច្ឆេទនៃការអនុញ្ញាតិដល់ការវាយតំលៃ | ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៦ |
| កាលបរិច្ឆេទនៃការអនុមត័ពីក្រុមប្រឹក្សាភិបាល | ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ |

## ១. ស្ថានភាពប្រទេស និងវិស័យបសុបក្សី

## សេចក្តីផ្តើម

ការរាលដាលមិនឈប់ឈរនៃជម្ងឺផ្តាសាយបក្សីដែលមានអត្រាឆ្លងខ្ពស់ នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ បានបង្កឱ្យការខូចខាតជាច្រើនដល់ឧស្សាហកម្មបសុបក្សីនៅក្នុងតំបន់ជាច្រើននៃពិភពលោក បានបង្កអោយអោយមានការបាត់បង់ជីវិតមនុស្សមួយចំនួន និងបានបង្កអោយការព្រួយបារម្ភអំពីគាំឆ្លងរាលដាលជាសាកលនៅក្នុងចំណោមមនុស្ស ដែលអាចកើតមានឡើងនៅក្នុងពេលណាមួយ[១] ។ ការឆ្លងរាលដាលទ្រង់ទ្រាយធំ បានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៣ នៅក្នុងប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ហើយឥឡូវនេះជម្ងឺផ្តាសាយបក្សីដែលមានអត្រាឆ្លងខ្ពស់នេះ បានរាលដាលដល់ អ៊ឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងលិច ។ ពពួកសត្វសាបជាង១៥០លានក្បាល បានស្លាប់ដោយសារជម្ងឺនេះ ឬត្រូវបានសំលាប់ ដែលជាផ្នែកមួយនៃការខំប្រឹងប្រែងទប់ស្កាត់ជម្ងឺផ្តាសាយបក្សីនេះ ។ ការខូចខាតផ្នែកសេដ្ឋកិច្ច ដែលគិតតែក្នុងវិស័យបសុសត្វតែប៉ុណ្ណោះនៅអាស៊ី ត្រូវបានគេប៉ាន់ប្រមាណថាមានតំលៃប្រហែលជា ១០កោដដុល្លារអាមេរិក ។ គ្រួសារកសិករក្រីក្ររាប់លានគ្រួសារ ដែលបានពឹងផ្អែកទៅលើបសុសត្វសំរាប់ការប្រើប្រាស់នៅក្នុងជីវភាពគ្រួសារ និងប្រាក់ចំណូលនោះបានទទួលរងនូវការខូចខាតច្រើនគេ នៅក្នុងចំណាមការខូចខាតទាំងនេះ ។

មានករណីមនុស្សចំនួន ៣១៧ករណី ដែលត្រូវបានបញ្ជាក់ដោយមន្ទីរពិសោធន៍ថា បានឆ្លងជម្ងឺគ្រុនផ្តាសាយបក្សី ដែលមានអត្រាឆ្លងខ្ពស់នេះ (ដែលក្រោយមកត្រូវបានហៅថាជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស ឬ AHI) គិតចាប់តាំងពី ឆ្នាំ ២០០៣ ហើយនៅក្នុងចំណោមករណីទាំងនេះ មានមនុស្សចំនួន ១៩១នាក់បានស្លាប់ ។ ស្ទើរតែគ្រប់ករណីទាំងអស់ ដែលត្រូវបានរាយការណ៍បញ្ជាក់ច្បាស់លាស់នោះ ត្រូវបានគេដឹងថាមានការពាក់ព័ន្ធជាមួយនឹងបក្សី ហើយរហូតដល់ពេលនេះ ជម្ងឺផ្តាសាយបក្សី និងមនុស្សមិនងាយនឹងឆ្លងរោគពីមនុស្សទៅមនុស្សទេ ។ ប៉ុន្តែ វីរុសនេះកំពុងតែមានការវិវត្តន៍ ហើយវិរុសនេះត្រូវបានគេជឿថាអាចបង្កបាននូវរូបលក្ខណៈដែលអាចនឹងនាំអោយមានការចម្លងពីមនុស្សទៅកាន់មនុស្ស[២] ប្រកបដោយប្រសិទ្ធិភាព ។ រាល់ករណីថ្មីនីមួយៗ នៃការឆ្លងទៅក្នុងខ្លួនមនុស្ស ផ្តល់ឱកាសដល់វីរុស អោយបង្កើននូវលទ្ធភាពចំលងរោគរបស់វាទៅក្នុងមនុស្ស នឹងដោយសារហេតុនេះវាវិវត្តទៅជាប្រភេទមេរោគដែលបង្កអោយ មានការរាលដាលជាសកល ។ ការាត្បាតថ្មីៗនៃវីរុសនេះ នៅក្នុងចំណោមសត្វស្លាបចិញ្ចឹម និងបក្សាបក្សីព្រៃនៅក្នុងតំបន់ថ្មីៗទៀត បានបង្កើននូវឱកាសបន្ថែមទៀតដែលអាចបង្កអោយមានករណីឆ្លងទៅក្នុងខ្លួនមនុស្សកើតឡើង ។ នៅក្នុងពេលដែលគេមមិនអាចធ្វើការទស្សន៍ទាយបានថា តើការរាលដាលជាសាកលម្តងទៀតនឹងកើតឡើងនៅពេលណា

[១] ជម្ងឺគ្រុនផ្តាសាយបក្សីឬ"ជម្ងឺផ្តាសាយសត្វស្លាប" គឺជាជម្ងឺឆ្លងនៅក្នុងចំណោមពពួកសត្វ ដែលបង្កឡើងដោយវីរុស ដែលតាមធម្មតាឆ្លងតែក្នុងចំណោមសត្វបក្សីប៉ុណ្ណោះ និងមានការឆ្លងតិចតួចនៅក្នុងចំណោមសត្វជ្រូក ។ វីរុសជម្ងឺគ្រុនផ្តាសាយបក្សីកើតមានឡើងតែនៅក្នុងអម្បូរសត្វជាក់លាក់ប៉ុណ្ណោះ ប៉ុន្តែនៅក្នុងករណីដ៏កម្រ វាបានឆ្លងពីសត្វទៅកាន់មនុស្ស ។ នៅក្នុងចំណោមបក្សីក្នុងស្រុក ការឆ្លងវីរុសជម្ងឺគ្រុនផ្តាសាយបក្សីបង្កឱ្យមានជំងឺដែលមានទំរង់សំគាល់ធំៗចំនួនពីរ អាស្រ័យទៅលើភាពខ្លាំងឬខ្សោយនៃភាពកាចសាហាវរបស់មេរោគ។ ទំរង់ដែលមានអត្រាចំលងរោគទាប បង្កឱ្យមានរោគសញ្ញាស្រាល និងអាចអោយគេមិនអាចដឹងបាន ។ ទំរង់ដែលមានអត្រាឆ្លងរោគខ្ពស់ ឆ្លងរាលដាលយ៉ាងឆាប់រហ័សនៅក្នុងចំណោមបសុបក្សី បង្កអោយមានជំងឺដែលប៉ះពាល់ដល់សរីរាង្គខាងក្នុងជាច្រើន និងដែលមានអត្រាស្លាប់អាចដល់ ១០០% ជារឿយៗ នៅក្នុងរយៈពេល ៤៨ម៉ោង ។ H5N1 គឺជាប្រភេទនៃវីរុសគ្រុនផ្តាសាយបក្សីដែលមានអត្រាចំលងរោគខ្ពស់ ។

[២] វីរុសអាចពង្រឹងនូវលទ្ធភាពចំលងរបស់វានៅក្នុងចំណោមមនុស្សតាមរយៈយន្តការសំខាន់ៗពីរ ។ យន្តការទី ១ គឺភាពមានប្រភពច្រើននៃមេរោគ ដែលនៅក្នុងនោះសារធាតុហ្សែន បានផ្លាស់ប្តូរគ្នាទៅវិញទៅមករវាងវីរុសរបស់មនុស្ស និងវីរុសរបស់សត្វ នៅក្នុងអំឡុងពេលដែលមានការឆ្លងរួមគ្នា នៅក្នុងចំណោមមនុស្ស និងសត្វជ្រូក ។ ការមានប្រភពមេរោគច្រើនបែបនេះ អាចបង្កឱ្យមាននូវប្រភេទវីរុសដែលមានលទ្ធភាពចំលងពេញលេញ ដែលអាចអោយមានការរាលដាលជំងឺជាសាកល ដែលត្រូវបានគេដឹងដោយសារមានករណីជំងឺដោយគំហុក ដោយមានរាលដាលយ៉ាងខ្លាំង ។ យន្តការទី ២ គឺជាដំណើរការសន្សឹមៗនៃការវិវត្តន៍ប្រែប្រួលរបស់សារធាតុហ្សែន ដែលតាមរយៈការប្រែប្រួលនេះ លទ្ធភាពរបស់មេរោគក្នុងការភ្ជាប់ខ្លួនទៅនឹងកោសិកាមនុស្សត្រូវបានពង្រឹង នៅក្នុងពេលនៃការឆ្លងជាបន្តបន្ទាប់ទៀតនៅក្នុងចំណោមមនុស្ស ។ ការវិវត្តន៍ប្រែប្រួលរបស់មេរោគប្រកបដោយសំរបសំរួលបែបនេះ ដែលត្រូវបានបង្ហាញនៅក្នុងដំណាក់កាលដំបូងដោយមានករណីមនុស្សមួយចំនួនតូច ព្រមទាំងភ័ស្តុតាងខ្លះៗអំពីការឆ្លងរោគពីមនុស្សទៅមនុស្សនោះ នឹងផ្តល់អោយពិភពលោកនូវពេលវេលាខ្លះ ដើម្បីធ្វើការចាត់វិធានការការពារ ។

និងថា តើវាមានភាពធ្ងន់ធ្ងរក៏រិតណានោះ លទ្ធភាពនៃការរាលដាលជាសាកល ពិតជាមានការកើនឡើង ។ ប្រសិនបើវីរុសនេះ សំរេចបាននូវលទ្ធភាពឆ្លងរោគខ្ពស់បំផុតក្នុងចំណោមមនុស្ស ហើយមានរោគសមុដ្ឋានខ្ពស់ថែមទៀតបន្ទាប់មកទៀត ជម្ងឺរាលដាលមនុស្សយ៉ាងធ្ងន់ធ្ងរមួយ អាចបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្សយ៉ាងសន្ធឹកសន្ធាប់ និងការបំផ្លិចបំផ្លាញ និងការខូចខាតសេដ្ឋកិច្ចយ៉ាងច្រើននៅកំរិតពិភពលោក ។

ការឆ្លើយតបពិភពលោកទៅនឹងការគំរាមគំហែងនៃជម្ងឺផ្តាសាយបក្សី និងមនុស្ស (AHI) នៅក្នុងមនុស្ស និងនៅក្នុងបសុបក្សីមានយុទ្ធសាស្ត្រសំខាន់បី (i) ដោយការត្រួតពិនិត្យ និងការលុបបំបាត់នូវភាពរាលដាលនៃជម្ងឺ បសុសត្វដោយប្រសិទ្ធិភាព ដោយហេតុនេះ ត្រូវបញ្ចុះបន្ទុកវីរុសដែលមានប្រភពពីបសុសត្វនៅក្នុងបរិស្ថាន និងដោយកាត់បន្ថយនូវគ្រោះថ្នាក់នៃការឆ្លងពីមនុស្ស (ii) ដោយការការពារនិងការកំណត់នូវភាពរាលដាលនៃជម្ងឺនៅក្នុងចំណោមមនុស្ស ដោយហេតុនេះ ត្រូវកាត់បន្ថយឱកាសរាលដាលសំរាប់វីរុសដែលត្រូវជួយឱ្យមានលទ្ធភាពឆ្លងទៅមនុស្ស ហើយ (iii) នៅក្នុងព្រឹត្តិការណ៍ឆ្លងរោគរាលដាលនោះ ដោយជួយប្រជាជនដែលមានផលប៉ះពាល់នោះ ដោះស្រាយនូវផលវិបាករបស់ខ្លួន ។ ការការពារ និងការត្រួតពិនិត្យជម្ងឺផ្តាសាយបក្សី និងមនុស្ស(AHI) ពាក់ព័ន្ធជាមួយអ្នកដើរតួរជាច្រើន នៅក្នុងវិស័យនៃសុខាភិបាល កសិកម្ម ការឆ្លើយតបនឹងគ្រោះមហន្តរាយធម្មជាតិហិរញ្ញវត្ថុ និងផែនការ ហើយដោយហេតុនេះ វិធីសាស្ត្រតាមពហុវិស័យ គឺជាការចាំបាច់បំផុត ។ គេទទួលស្គាល់ផងដែរថា ប្រទេសនីមួយៗ គឺមានសារៈសំខាន់ចំពោះការឆ្លើយតបនឹងពិភពលោកដែលមានលក្ខណៈសម្របសម្រួល និងមានប្រសិទ្ធិភាព ។ យុទ្ធសាស្ត្ររបស់ប្រទេសគួរតែត្រូវបានបង្កើតឡើងដោយអនុលោមតាមតម្រូវការ និងកាលៈទេសៈតាមប្រទេសជាក់លាក់ ហើយ យុទ្ធសាស្ត្រទាំងនេះគួរតែត្រូវបានរៀបចំឡើងដោយរដ្ឋាភិបាលនីមួយៗ ដែលប្រឈមនឹងការគម្រាមគំហែងនៃជម្ងឺផ្តាសាយបក្សី និងមនុស្ស (AHI) ។

## ស្ថានភាពក្នុងតំបន់

នៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ករណីនៃជម្ងឺផ្តាសាយបក្សីនិងមនុស្ស បានកើតឡើងនៅក្នុងប្រទេសជាច្រើន រួមមាន កម្ពុជា ចិន ឡាវ ឥណ្ឌូនេស៊ី ជប៉ុន កូរ៉េ មាឡេស៊ី ភូមិមា ថៃ និង វៀតណាម ។ ការឆ្លើយតបនឹងការឆ្លងរាលដាល នៅក្នុងចំណោមពពួកបក្សាបក្សីក្នុងស្រុក និងបក្សាបក្សីក្នុងព្រៃ បានរួមបញ្ចូលនូវការពិនិត្យវិភាគ ការឃ្លាំមើល ការប្រុងប្រយ័ត្ននៅតាមព្រំដែន ការត្រួតពិនិត្យចលនាបក្សីនៅក្នុងប្រទេស កម្មវិធីសំលាប់បក្សី និងការត្រួតពិនិត្យជលដ្ឋានបក្សាបក្សីព្រៃ ។ អង្គការសុខភាពសត្វពិភពលោក (OIE) បានរាយការណ៍ថា នៅក្នុងឆ្នាំ ២០០៤ មានសត្វស្លាបប្រមាណជាង ៦០លានក្បាល ត្រូវបានសំលាប់ និងប្រហែល ១៣១លានក្បាល ត្រូវបានចាក់វ៉ាក់សាំងការពារ ។ ការឆ្លើយតបនេះ បានកើតឡើងនៅក្នុងពេលដែលមានការឆ្លងរាលដាលជាង ៨០០ដង ដោយមានករណីឆ្លងជំងឺជាង ២២លានករណី (តួលេខនេះ គិតបញ្ចូលទាំងបក្សាបក្សីដែលឈឺ និងបក្សាបក្សីដែលបានងាប់ដោយសារជម្ងឺនេះ) និងបក្សាបក្សីជាង ៤ លានក្បាលដែលងាប់ដោយសារជម្ងឺផ្តាសាយបក្សី និងមនុស្សនេះ ។ នៅក្នុងផ្នែកសុខភាពមនុស្ស គិតចាប់តាំងពីឆ្នាំ ២០០៣ រហូតដល់បច្ចុប្បន្ននេះ មានជម្ងឺចំនួន ២៣០ករណី ដែលត្រូវបានរាយការណ៍នៅក្នុងប្រទេស កម្ពុជា ចិន ឥណ្ឌូនេស៊ី ថៃ និងវៀតណាម ដែលបានធ្វើអោយមានមនុស្សស្លាប់ចំនួន ១៤៣នាក់ ដោយសារជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស (AHI) នេះ ។

## ២. គោលបំណង

## ហេតុផលដែលនាំអោយមានការចូលរួមពីសំណាក់ធនាគារ

ហេតុផលដ៏សំខាន់ ដែលនាំអោយមានការចូលរួមពីសំណាក់ធនាគារនោះ គឺការយល់ឃើញរបស់ពិភពលោកនៅការទប់ស្កាត់ជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស ។ ក៏មានទស្សនៈបែបនេះផងដែរនៅក្នុងកំរិតថ្នាក់ជាតិ ដែលនាំអោយប្រទេសនានាធ្វើការពង្រឹងសេវាបសុពេទ្យការឃ្លាំមើលជម្ងឺ និងប្រព័ន្ធសុខភាពមនុស្ស ដូចដែលត្រូវបានធ្វើផែនការឡើងនៅក្នុងប្រតិបត្តិការនេះ ។ កម្មវិធីទប់ស្កាត់ជម្ងឺផ្តាសាយបក្សី និងមនុស្សទាមទារអោយមានការប្រើប្រាស់វិធីសាស្រ្តពហុវិស័យ ដើម្បីដាក់បញ្ចូលគ្នានូវបញ្ហាបច្ចេកទេស សង្គមកិច្ច សេដ្ឋកិច្ច នយោបាយ គោលនយោបាយ និងនិយ័តិកម្ម នៅក្នុងការដោះស្រាយបញ្ហាស្មុគស្មាញ ។ ធនាគារមានលក្ខណៈសមស្របក្នុងការប្រើប្រាស់នូវមូលដ្ឋានចំណេះដឹងរបស់ខ្លួន ស្តីអំពីវិធីសាស្រ្តពហុវិស័យ ដែលគេត្រូវការនៅក្នុងប្រតិបត្តិការដែលត្រូវបានស្នើរឡើងនេះ និងក្នុងការប្រើប្រាស់ភ័ស្តុតាង និងមេរៀនដែលទទួលបានមកពីក្នុងតំបន់នានា នៅក្នុងការឆ្លើយតបទៅនឹងគ្រោះអាសន្ន ។ ធនាគារក៏អាចជួយផងដែរ ក្នុងការគៀងគរនូវក្រសួងនានាដែលពាក់ព័ន្ធ ទីភ្នាក់ងាររដ្ឋាភិបាល និងសហគមន៍ផ្តល់ជំនួយ និងក្នុងការធានាអោយមាន នូវការសំរបសំរួលផ្នែកនយោបាយជាន់ខ្ពស់ ។

ធនាគារ បាននិងកំពុងធ្វើកាជាមួយអង្គការសុខភាពពិភពលោក អង្គការ FAO, អង្គការ OIE, ពហុភាគី ទ្វេភាគី និងដៃគូដទៃទៀតនៅក្នុងប្រទេស និងនៅឆាកអន្តរជាតិ ដើម្បីធ្វើការរៀបចំកម្មវិធីពិភពលោកប្រយុទ្ធប្រឆាំងនឹងជម្ងឺផ្តាសាយបក្សី ការត្រៀមលក្ខណៈ និងការឆ្លើយតបទៅនឹងការរាលដាលជម្ងឺជាសាកល នៅក្នុងចំណោមមនុស្ស ។ នៅក្នុងប្រទេសកម្ពុជា ធនាគារបាននិងកំពុងធ្វើការជាមួយអង្គការ UNDP (ដែលអ្នករៀបចំការប្រជុំតុមូលរបស់ម្ចាស់ជំនួយ) ទីភ្នាក់ងារដទៃទៀតនៅក្នុងព្រ័ន្ធអង្គការសហប្រជាជាតិ (អង្គការ FAO, អង្គការ WHO, អង្គការ UNICEF) សហគមន៍អ៊ឺរ៉ុប និងដៃគូដទៃទៀត ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការយតំលៃ និងកែលំអផែនការជាតិស្តីពីជម្ងឺផ្តាសាយបក្សី និងមនុស្ស ។ ធនាគារ អាចជួយប្រទេសកម្ពុជាក្នុងការប្រមែរប្រមូលនូវធនធានបន្ថែមពីសំណាក់ទីភ្នាក់ងារទ្វេភាគី និងទីភ្នាក់ងារអន្តរជាតិ ។ ក្រៅពីនេះ ជំនួយបច្ចេកទេសដែលបានផ្តល់ឱ្យដោយធនាគារមានសារៈសំខាន់ណាស់នៅក្នុងស្ថានភាពគ្រោះអាសន្នប្រហាក់ប្រហែលគ្នានេះនៅក្នុងពិភពលោក ឬក្នុងតំបន់ដូចជាជំងឺ SARS និងការកសាងឡើងវិញ ក្រោយគ្រោះមហន្តរាយ ។ ធនាគារនេះ មានគុណសម្បត្តិនៅក្នុងការផ្តល់នូវជំនាញ និងទស្សនៈអន្តរវិស័យ និងមាន គុណសម្បត្តិនៅក្នុងការដោះស្រាយបញ្ហាស្ថាប័ន ក្នុងការឆ្លើយតបទៅនឹងគ្រោះអាសន្ន ។ ធនាគារនេះក៏អាចផ្តល់នូវ បទពិសោធន៍ និងជំនាញជាច្រើន នៅក្នុងការស្វែងយល់ដឹង និងការដោះស្រាយនូវផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច ។

## លក្ខណៈសមស្របរបស់ប្រទេស នៅក្រោមល័ក្ខខ័ណ្ឌនៃកម្មវិធីពិភពលោកប្រយុទ្ធប្រឆាំងនឹងជម្ងឺផ្តាសាយបក្សី, ការត្រៀមលក្ខណៈ និងការឆ្លើយតបទៅនឹងការរាលដាលជម្ងឺជាសាកលនៅក្នុងចំណោមមនុស្ស

គម្រោងដែលត្រូវបានស្នើរឡើងនេះមានលក្ខណៈស្របទៅតាមកម្មវិធីពិភពលោកប្រយុទ្ធប្រឆាំងនឹងជម្ងឺផ្តាសាយបក្សី ត្រៀមលក្ខណៈ និងឆ្លើយតបទៅនឹងការរាលដាលជម្ងឺជាសាកលនៅក្នុងចំណោមមនុស្ស (GPAI) ដែលត្រូវបានអនុម័តដោយគណៈកម្មការនាយករបស់ធនាគារ នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០៦ ។ ការឧបត្ថម្ភគាំទ្រសំរាប់កម្មវិធីពិភពលោកប្រយុទ្ធប្រឆាំងនឹងជម្ងឺផ្តាសាយបក្សី ការត្រៀមលក្ខណៈ និងការឆ្លើយតបទៅនឹងការរាលដាលជម្ងឺ ជាសាកលនៅក្នុងចំណោមមនុស្ស (GPAI) ត្រូវបានគេផ្តល់អោយ តាមរយៈការប្រើប្រាស់នូវឥណទានកម្មវិធីដែលអាចកែតំរូវបាន (Adaptable Program Loan - APL) និងនៅក្នុងក្របខណ្ឌនៃការសម្របសម្រួលពិភពលោក ។ នៅក្រោមក្របខ័ណ្ឌឥណទានកម្មវិធីដែលអាចកែតំរូវបាន (APL)

ប្រទេសនីមួយៗ អាចទទួលនូវប្រាក់កម្ចីឥណទាន និងជំនួយដាច់ដោយឡែកពីគ្នា ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងជាតិផ្ទាល់ខ្លួនរបស់ពួកគេ នៅក្នុងរង្វង់ទឹកប្រាក់សរុបចំនួន ៥០០លានដុល្លារអាមេរិក ។ ដោយហេតុថាកម្មវិធី GPAI នេះ ត្រូវបានរៀបចំឡើងដើម្បីផ្តល់ហិរញ្ញប្បទាន គ្រោះអាសន្នដល់ប្រទេសដែលជាសមាជិក ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺគ្រុនផ្តាសាយបក្សី តាមរយៈវិធានការរកឃើញជំងឺទាន់ពេលវេលា និងឆ្លើយតបបានឆាប់រហ័សនោះ ប្រតិបត្តិការសំរាប់ប្រទេសជាក់លាក់ នឹងត្រូវបានពិនិត្យពិចារណារនៅក្រោមគោលនយោបាយគ្រោះអាសន្ន OP/BP 8.50 របស់ធនាគារ ។ កម្មវិធី GPAI នឹងចាត់ទុកគម្រោង ឆ្លើយតបទៅនឹងគ្រោះអាសន្នជាក់លាក់ នៅក្នុងប្រទេសនីមួយៗថាជា "ដំណាក់កាល" នៃឥណទានកម្មវិធីដែលអាចកែតំរូវបាន (APL) (វិធីសាស្រ្តប្រហាក់ប្រហែលគ្នានេះ រួមមានកម្មវិធីមេរោគអេដស៏/ជម្ងឺអេដស៏ពហុប្រទេស សំរាប់តំបន់អាហ្រ្វិក និងតំបន់ ការីប៊ីន) ។ ប្រទេសកម្ពុជាពិតជាបានបំពេញនូវលក្ខណៈវិនិច្ឆ័យសមស្រប ដូចដែលត្រូវបានបញ្ជាក់នៅក្នុងឯកសារនៃកម្មវិធីពិ GPAI ពីព្រោះថា (i) កម្ពុជាគឺជាប្រទេសស្ថិតនៅក្នុង "ស្ថានភាពរាលដាល" (ដោយមានការរាលដាលជំងឺនៅក្នុងចំណោមបសុបក្សី និងមានមនុស្សស្លាប់ចំនួន ៦នាក់) (ii) ផែនការជាតិស្តីពីជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស (សូមមើលកថាខណ្ឌខាងលើ) ដែលរួមបញ្ចូលគ្នានូវផែនការសុខភាពសត្វ និងសុខភាពមនុស្ស ត្រូវបានរៀឡើងនិងអនុម័តដោយរដ្ឋាភិបាល និង (iii) សកម្មភាពដែលត្រូវបានដាក់ញ្ចូលនៅក្នុងគម្រោង ដែលបានស្នើរឡើងនេះ មានលក្ខណៈស្របគ្នាពេញលេញជាមួយទិសដៅ និងសេចក្តីថែងនៅក្នុងកម្មវិធី GPAI ។

## ៣. បញ្ហាប្រទេស និងវិស័យ

ប្រទេសកម្ពុជា សំរេចបាននូវស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ហើយចាប់តាំងពីឆ្នាំ ១៩៩៣ កម្ពុជាបាននិងកំពុងទទួលបាននូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ។ ទោះបីជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចរបស់កម្ពុជា នៅតែមានភាពងាយរងគ្រោះ ហើយកំណើនសេដ្ឋកិច្ចមិនបាននាំអោយមាននូវការកាត់បន្ថយភាពក្រីក្រទូទៅទេ ។ ជាមួយផលិតផលសរុបក្នុងស្រុកសំរាប់មនុស្សម្នាក់ដែលមានចំនួន ៣៩០ដុល្លារអាមេរិក (ក្នុងឆ្នាំ ២០០៥) និងសូចនាករសង្គមដែលបង្ហាញអំពីវឌ្ឍនភាពតិចតួចចាប់តាំងពីទស្សវត្សឆ្នាំ ១៩៦០ មកនោះ កម្ពុជានៅតែជាប្រទេសមួយនៅក្នុងចំណោមប្រទេសក្រីក្របំផុតនៅក្នុងពិភពលោក ។ ប្រជារាស្រ្តប្រហែលជា ៣៥% បានស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិ ដោយមានប្រជារាស្រ្តប្រហែល ១៥% បានរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ។ ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា មានច្រើនលើសលុប នៅក្នុងតំបន់ខាងក្រៅទីក្រុងភ្នំពេញ ដែលមានបាតុភាពក្រីក្រលើសពី ៥០% នៅក្នុងតំបន់ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ។

ប្រទេសកម្ពុជា គឺជាប្រទេសមួយនៅក្នុងចំណោមប្រទេសដំបូងគេនៅក្នុងតំបនអាស៊ីអាគ្នេយ៏ ដែលជួបប្រទះនូវការឆ្លងជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស ។ ករណីទី ១ នៃការឆ្លងជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស នៅក្នុងប្រទេសកម្ពុជា ត្រូវបានរាយការណ៏នៅក្នុង ខែធ្នូ ឆ្នាំ ២០០៣ ហើយរលកទី ១នៃការរាលដាលជំងឺ ក្នុងអំឡុងខែមករា ដល់ខែឧសភាឆ្នាំ ២០០៤ បានផ្តល់នូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កសិករខ្នាតតូច ដែលបានចិញ្ចឹមបសុបក្សីភាគច្រើនក្នុងប្រទេស ដើម្បីបំរើជីវភាព និងធ្វើអាជីវៈកម្មបសុបក្សីខ្នាតតូច។ ករណីឆ្លងជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស បានកើតឡើងសារជាថ្មីម្តងទៀតនៅចុងឆ្នាំ ២០០៤ និងដើមឆ្នាំ ២០០៥ ហើយករណីមនុស្សចំនួន ៤នាក់ (ស្លាប់ទាំងអស់) ត្រូវបានរាយការណ៏នៅក្នុងឆ្នាំ ២០០៥ ។ មានការរាលដាលជំងឺនៅក្នុងចំណោមសត្វមាន់ សត្វទា និងមាន់ជល់ នៅក្នុង ខែកុម្ភៈ ឆ្នាំ ២០០៦ ហើយករណីនេះត្រូវបានទប់ស្កាត់ភ្លាមៗ (បក្សីប្រហែល ២៥០០ក្បាលបានស្លាប់ដោយជម្ងឺ ឬ ត្រូវបានសំលាប់នៅក្នុងពេលរាលដាលក្នុងខែកុម្ភៈឆ្នាំ ២០០៦) ដែលបណ្តាលឱ្យមានមនុស្សស្លាប់ ២នាក់ក្នុងឆ្នាំ ២០០៦ ។ មនុស្សម្នាក់ទៀតបានស្លាប់ដោយសារការឆ្លងវីរុសជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស ត្រូវបានបញ្ជាក់នៅក្នុងឆ្នាំ២០០៧ ។

ការរាលដាលជំងឺម្តងហើយម្តងទៀត និងការបាត់បង់អាយុជីវិតមនុស្ស និងការខូចខាតជីវភាព ដែលបង្កឡើងដោយជំងឺនេះ បានបង្ហាញយ៉ាងច្បាស់លាស់ថាប្រទេសកម្ពុជា នៅតែខ្វះខាតប្រព័ន្ធឃ្លាំមើលជម្ងឺដែលមានប្រសិទ្ធភាព និងខ្វះខាតសមត្ថភាពទប់ស្កាត់ជម្ងឺនេះ ។

ប្រទេសកម្ពុជា គឺស្ថិតនៅក្នុងចន្លោះប្រទេសចំនួន ២ ដែលចិញ្ចឹមបសុបក្សីខ្នាតធំ-វៀតណាម និងថៃ - ប្រទេសទាំងពីរនេះ បានជួបប្រទះនូវការរាលដាលនៃជម្ងឺផ្តាសាយបក្សីនេះក្នុងទ្រង់ទ្រាយធំជាងប្រទេសកម្ពុជា និងការឆ្លងជំងឺដល់មនុស្សជាច្រើននាក់ ។ អនុតំបន់នេះ គឺជាកន្លែងដែលងាយបង្កអោយមានការផ្ទុះរាលដាលនៃជម្ងឺផ្តាសាយបក្សី និងការកើតឡើងនូវប្រភេទមេរោគជម្ងឺផ្តាសាយ ដែលបង្កអោយមានការរាលជាសាកលនៅក្នុងចំណោមមនុស្ស ។ ឥឡូវនេះ រាជរដ្ឋាភិបាល បានផ្តោតការយកចិត្តទុកដាក់ទៅលើបង្កើតឡើងនូវផែនការរួម សំរាប់ទប់ស្កាត់ជម្ងឺគ្រុនផ្តាសាយបក្សី ត្រៀមលក្ខណៈ និងឆ្លើយតបទៅនឹងការរាលដាលជាសាកលនៅក្នុងចំណោមមនុស្ស និងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៏អន្តរជាតិ ដើម្បីកសាងសមត្ថភាពរបស់ខ្លួនសំរាប់ការឃ្លាំមើលជម្ងឺ ការស៊ើបអង្កេតនូវរាលដាលជម្ងឺ និងការឆ្លើយតបចំពោះគ្រោះអាសន្ន ។

## ៤. ការពិពណ៌នាអំពីគម្រោង

ស្របគ្នាជាមួយនឹងកម្មវិធី GPAI ទិសដៅរួមរបស់គម្រោងនេះ គឺដើម្បីគាំទ្រដល់ការអនុវត្តន៏ផែនការជាតិ ស្តីពីជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស ដែលត្រូវបានរៀបចំឡើង ដើម្បីធ្វើអប្បរិមាកម្មនូវការគំរាមគំហែងចំពោះមនុស្ស និងវិស័យបសុបក្សីដោយសារការឆ្លងរោគជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្សនៅក្នុងប្រទេសកម្ពុជា និងដើម្បីធ្វើការត្រៀមលក្ខណៈ ទប់ស្កាត់ និងឆ្លើយតប (ប្រសិនបើចាំបាច់) ទៅនឹងការរាលដាលជាសាកលនៃជម្ងឺផ្តាសាយមនុស្ស ។ ពិសេសជាងនេះទៀត គម្រោងនេះត្រូវបានគេរំពឹងថានឹងផ្តល់ការគាំទ្រផ្ទាល់ដល់ការអនុវត្តន៏ផែនការជាតិស្តីពីជម្ងឺគ្រុន ផ្តាសាយបក្សី និងមនុស្ស ដើម្បីសំរេចបាននូវលទ្ធផលដូចតទៅ: (ក) ទប់ស្កាត់ការរាលដាលនៃជម្ងឺ ដែលនាំអោយមានការកាត់បន្ថយនូវការខូចខាតដល់ជីវភាពអ្នកចិញ្ចឹមបសុបក្សីសំរាប់អាជីវកម្ម និងសំរាប់ជីវភាព និងការកាត់បន្ថយនូវការខូចខាតដល់ឧស្សាហកម្មបសុបក្សី និងការកាត់បន្ថយការឆ្លងមេរោគនៅក្នុងបរិស្ថាន (ខ) ការពារ ឬកាត់បន្ថយនូវភាពមានជម្ងឺ និងមរណភាពរបស់មនុស្ស តាមរយៈការកាត់បន្ថយនូវឱកាសចម្លងរោគដល់មនុស្ស និងការពង្រឹងសមត្ថភាពថែទាំព្យាបាល (គ) ការពារ ឬទប់ស្កាត់នូវការអាក់ខាន និងការខូចខាតផ្នែកម៉ាក្រូសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយនូវលទ្ធភាពរាលដាលជាសាកលនៅក្នុងចំណោមមនុស្ស និងតាមរយៈការលើកកំពស់នូវការត្រៀមលក្ខណៈ និងការឆ្លើយតបចំពោះគ្រោះអាសន្ន ។

## សមាសធាតុនៅក្នុងគម្រោង

គម្រោងដែលត្រូវបានស្នើឡើងនេះ នឹងធ្វើការផ្តល់ហិរញ្ញប្បទានដល់សកម្មភាព ដែលស្របគ្នាពេញលេញជាមួយនឹង ទិសដៅ និងការពិពណ៌នានៅក្នុងផែនការជាតស្តីពីជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស ដោយផ្តោតលើការធ្វើហិរញ្ញប្បទាន ដល់សកម្មភាពដែលមិនត្រូវបានផ្តល់មូលនិធិ ដោយអ្នកផ្តល់ហិរញ្ញប្បទានដទៃទៀត (បច្ចេកទេស និងហិរញ្ញវត្ថុ)។ គម្រោងនេះ នឹងរួមបញ្ចូលនូវសមាសធាតុចំនួន ៣ ដែលត្រូវបានសង្ខេបដូចខាងក្រោម:

សមាសធាតុ ក-ប្រព័ន្ធសុខភាពបសុសត្វៈ (ការចំណាយសរុបប្រហែល ៥.៨០លានដុល្លារអាមេរិក) ទិសដៅរបស់សមាសធាតុសុខភាពសត្វ គឺដើម្បីធ្វើអប្បបរមាកម្មនូវភិរិតនៃការឆ្លងជាមួយវីរុស H5N1នៅក្នុងប្រទេសកម្ពុជា [៣] ។ ទិសដៅរបស់សមាសធាតុនេះ នឹងត្រូវបានសំរេចបានតាមរយៈអនុសមាសធាតុចំនួន ៦ (អនុសមាសធាតុធំមានចំនួន ៤ និងអនុសមាសធាតុតូចមានចំនួន ២) ។ អនុសមាសធាតុទី ១ នឹងត្រូវពង្រឹងសេវាបសុសត្វ ចាប់ពីថ្នាក់កណ្តាលរហូតដល់ថ្នាក់ភូមិ ដើម្បីលើកកំពស់សមត្ថភាពបង្ការ រកឃើញ និងឆ្លើយតបទៅនឹងជម្ងឺគ្រុនផ្តាសាយបក្សី និងជម្ងឺដទៃទៀត នៅក្នុងចំណោមពពួកសត្វ ។ ការងារនេះនឹងត្រូវសម្រេចបាន តាមរយៈការលើកកំពស់ និងការពង្រឹងធនធានបណ្តុះបណ្តាល ការពិនិត្យឡើងវិញនូវតម្រូវការ និងកម្មវិធីបណ្តុះបណ្តាលសំរាប់បណ្តុះបណ្តាលបសុពេទ្យនៅតាមភូមិ ការពង្រឹងការធ្វើរបាយការណ៍ពីសំណាក់បសុពេទ្យតាមភូមិដែលត្រូវបានបណ្តុះបណ្តាលទៅកាន់សេវាបសុពទ្យថ្នាក់ស្រុកការផ្តល់ធនធានដល់សេវាបសុពទ្យថ្នាក់ស្រុក និងថ្នាក់ខេត្តដើម្បីគាំទ្រដល់ការឆ្លើយតបទៅនឹងជម្ងឺ និងការបង្កើតច្បាប់សុខភាពសត្វសមស្រប ។ អនុសមាសធាតុទី ២ នឹងត្រូវផ្តល់ការបណ្តុះបណ្តាលស្តីពីការចាក់ថ្នាំបង្ការរោគ និងធនធានចាំបាច់សំរាប់អនុវត្តន៏ការឆ្លើយតបទៅនឹងគ្រោះអាសន្ន ។ ការសិក្សាដទៃខ្លះទៀតស្តីពីអេពីដេមសាស្ត្រ (រោគរាតត្បាត) រួមមាន ការសិក្សាអំពីអម្បូរបក្សីព្រៃ ក៏នឹងត្រូវបានធ្វើឡើងផងដែរនៅក្នុងអនុសមាសធាតុនេះ ។ អនុសមាសធាតុទី ៣ នឹងត្រូវពិនិត្យឡើងវិញនូវការប្រព្រឹត្តដែលមានគ្រោះថ្នាក់ខ្ពស់នៅក្នុងការផលិតក្នុងការលក់ដូរដែលបង្កលក្ខណៈងាយស្រួលដល់ការបន្តវត្តមាន និងការចម្លងរោគ ហើយនឹងត្រូវអនុវត្តនូវវិធានការសមស្រប ដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់ទាំងនេះ ។ អនុសមាសធាតុទី ៤ នឹងរួមបញ្ចូលនូវការសិក្សាបន្ថែមទៀតមួយចំនួនស្តីពីអេពីដេមសាស្ត្រ រួមទាំងការសិក្សាអំពីអម្បូរបក្សីព្រៃ ហើយនឹងត្រូវធ្វើការពង្រឹងនូវកម្មវិធី IEC ស្តីអំពីសុខភាពសត្វដែលមានស្រាប់ ។ អនុសមាសធាតុទី ៥ នឹងត្រូវពង្រឹងនូវការឆ្លើយតបផ្នែកបសុពេទ្យទៅនឹងការរាលដាលជំងឺជាសាកល និងអនុសមាសធាតុទី ៦ នឹងត្រូវផ្តល់នូវការឧបត្ថម្ភគាំទ្រដល់សមាសធាតុសុខភាពសត្វ ។

**សមាសធាតុ ខ - ប្រព័ន្ធសុខភាពមនុស្ស (ការចំណាយសរុបប្រហែល ៣.៥០លានដុល្លារអាមេរិក)** ទិសដៅរួមរបស់សមាសធាតុនេះ គឺដើម្បីបង្ការនូវការរាលដាលជំងឺជាសាកលនៅក្នុងចំណោមមនុស្សនៅក្នុងប្រទេសកម្ពុជា តាមរយៈការរកឃើញជាបន្ទាន់នូវករណីឆ្លងនៅក្នុងចំណោមមនុស្ស និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវករណីមនុស្ស ។ ការពង្រឹង ប្រព័ន្ធសុខាភិបាលសាធារណៈ នឹងជួយលើកកំពស់ដល់ការត្រៀមលក្ខណៈថ្នាក់ជាតិទប់ទៅនឹងការរាលដាលជាសាកល និងជួយកាត់បន្ថយនូវការបាត់បង់ជីវិតដែលបណ្តាលមកពីជម្ងឺឆ្លងរាលដាលជាសាកលនូវជម្ងឺផ្តាសាយនេះនៅក្នុងចំណោមមនុស្ស ។ <u>អនុសមាសធាតុទី ១</u> នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការបណ្តុះបណ្តាលដល់បុគ្គលិកថែទាំសុខភាព និងការបង្កើតឡើងនូវឯកសារសំរាប់ការប្រើប្រាស់ដោយអ្នកផ្តល់ការថែទាំសុខភាព និងបុគ្គលិកសុខភាពស្ម័គ្រចិត្តក្នុងភូមិ ។ ដើម្បីកែលំអនូវការឃ្លាំមើល ការស៊ើបអង្កេត និងការឆ្លើយតប <u>អនុសមាសធាតុទី ២</u> នឹងគាំទ្រដល់ការបណ្តុះបណ្តាល ក្រុមឆ្លើយតបជាបន្ទាន់ថ្នាក់ខេត្ត, គាំទ្រចំណាយប្រតិបត្តិដែលពាក់ព័ន្ធទៅនឹងការឃ្លាំមើល

---

៣

គោលដៅចុងក្រោយគឺការបំបាត់នូវជំងឺនេះប៉ុន្តែទោះបីជាគេអាចសំរេចបាននូវគោលដៅនេះក៏ដោយវាមិនអាចមានចីរភាពទេដរាបណាការឆ្លងរោគនេះនៅតែមាននៅក្នុងតំបន់និងមានការចរាចរនូវសត្វស្លាបនិងផលិតផលបសុបក្សីឆ្លងកាត់ព្រំដែនដោយខុសច្បាប់និងគ្មានការត្រួតពិនិត្យនោះ។ ការធ្វើការធ្វើអប្បរមាកម្មនូវឆ្លងរោគនៅក្នុងចំណោមបសុបក្សីនឹងជួយកាត់បន្ថយនូវគ្រោះថ្នាក់នៃការឆ្លងរោគដល់មនុស្សនិងការពារវិស័យបសុបក្សី និងជីវភាពរបស់អ្នកចិញ្ចឹមបសុបក្សីខ្នាត់តូចនិងក្រុមគ្រួសារកសិករក្រីក្រ ។ក្រៅពីនេះការកែលំប្រព័ន្ធសុខភាពសត្វនឹងជួយលើកកំពស់ផលិតភាពរបស់វិស័យបសុសត្វដែលផ្តល់អត្ថប្រយោជន៏ដល់អ្នកផលិតសត្វដើម្បីធ្វីអាជីវកម្មក៏ដូចជាអ្នកផលិតសត្វដើម្បីជីវភាពគ្រួសារ ។

ការស៊ើបអង្កេត និងការឆ្លើយតប និងគាំទ្រដល់ការដឹកជញ្ជូន សំរាប់អ្នកដែលអនុវត្តសកម្មភាពទាំងពីរនៅតាមមូលដ្ឋាន ក៏ដូចជាចំណាយសំរាប់ ការអភិបាលនៅតាមក៏រិតថ្នាក់នីមួយៗ ។ អ្នកជំនាញការអន្តរជាតិនឹងត្រូវបានជួលអោយមធ្វើការកំណត់នូវសកម្មភាពដែលចាំបាច់ ដើម្បីនូវធានាថាសកម្មភាពទាំនេះស្របទៅតាមបទបញ្ញត្តិសុខភាពអន្តរជាតិ（IHR） ហើយរបកគំហើញទាំងនេះនឹងត្រូវបានផ្សព្វផ្សាយ ។ ដើម្បីគាំទ្រដល់ការគ្រប់គ្រងករណី និងការទប់ស្កាត់ការឆ្លងរោគ អនុសមាសធាតុទី ៣ នឹងត្រូវផ្តល់ហិរញ្ញប្បទានដល់ការធ្វើលទ្ធកម្ម និងការចែកចាយឱសថ សំភារៈបរិក្ខាវេជ្ជសាស្រ្ត និងPPE ។ ការបណ្តុះបណ្តាលវេជ្ជសាស្រ្តស្តីអំពីការគ្រប់គ្រងករណីនិងការទប់ស្កាត់ការឆ្លងរោគ នឹងទទួលបាននូវការឧបត្ថម្ភគាំទ្រ ក៏ដូចជាការកំណត់ និងគ្រាំទ្រដល់សកម្មភាពដែលចាំបាច់ដើម្បីធានាអោយមាននូវការគ្រប់គ្រងករណី និងការទប់ស្កាត់ការឆ្លងរោគបានសបស្រប ។ អនុសមាសធាតុទី ៤ នឹងគាំទ្រដល់សកម្មភាពមន្ទីរពិសោធន៏តាមរយៈការបង្កើតឡើងនូវយុទ្ធសាស្រ្ត មន្ទីរពិសោធន៏ជាតិ ការអប់រំបន្ត និងវគ្គបណ្តុះបណ្តាលបំប៉នសំរាប់បុគ្គលិកមន្ទីរពិសោធន៏នៅនឹងកន្លែងធ្វើការ （ដោយប្រើប្រាស់នូវអ្នកណ្តុះបណ្តុលអន្តរជាតិ） ឬនៅក្នុងថ្នាក់មូលដ្ឋានដោយប្រើប្រាស់អ្នកបណ្តុះបណ្តាលដែលមានស្រាប់នៅក្នុងប្រទេស និងគាំទ្រដល់ការផ្តល់ការផ្តល់នូវឧបករណ៏សំភារៈបរិក្ខាសំរាប់ប្រមូលសំណាកសំភារៈ និងប្រតិករសំរាប់មន្ទីរពិសោធន៏ មធ្យោបាយដឹកជញ្ជូនសំណាកនៅខាងក្នុងប្រទេសកម្ពុជា ក៏ដូចជាការដឹងជញ្ជូនសំណាកទៅក្រៅប្រទេសទៅកាន់មន្ទីរពិសោធន៏បង្អែករបស់អង្គការសុខភាពពិភពលោក។ សកម្មភាពដែលពាក់ព័ន្ធទៅនឹងការត្រៀមលក្ខណៈទប់ទល់នឹងការរាលដាលជំងឺជាសាកលសំរាប់វិស័យសុខាភិបាល នឹងត្រូវបានគាំទ្រដោយអនុសមាសធាតុទី ៥ ហើយសកម្មភាពទាំងនេះរួមបញ្ចូលនូវការរៀបចំនិងការផ្សព្វផ្សាយផែនការ ការបណ្តុះបណ្តាលបុគ្គលិកថ្នាក់ខេត្ត ដើម្បីរៀបចំផែនការ និងការធ្វើសមយុទ្ធរបស់ពួកគេ ។ អនុសមាសធាតុទី ៦ នឹងគាំទ្រដល់សកម្មភាពទប់ស្កាត់ជាបន្ទាន់នូវការរាត្បាតនៃវីរុសជម្ងឺផ្តាសាយថ្មីដែលអាចបង្កអោយមាននូវជម្ងឺផ្តាសាយដែលឆ្លងរាលដាលជាសាកលៈការគ្រប់គ្រងករណី ការទប់ស្កាត់ការឆ្លងរោគឯកកោកម្ម/ការដាក់អោយនៅដាច់ពីគេសំភារៈបរិក្ខា និងការផ្គត់ផ្គង់ ។ សកម្មភាព នៅក្នុងអនុសមាសធាតុនេះ រួមបញ្ចូលនូវនូវការបង្កើតកម្មវិធីបណ្តុះបណ្តាលអំពីការទប់ស្កាត់ជំងឺជាបន្ទាន់សិក្ខាសាលា សំរាប់ការអនុវត្តន៏ផែនការទប់ស្កាត់ជំងឺជាបន្ទាន់ និងការបណ្តុះបណ្តាលអំពីការទប់ស្កាត់ជំងឺជាបន្ទាន់សំរាប់បុគ្គលិកថ្នាក់ មណ្ឌលសុខភាព/មន្ទីរពេទ្យ ខេត្ត ស្រុក និងក្រុមឆ្លើយតបបន្ទាន់ ក៏ដូចជាទាហាន ប៉ូលីស និងអាជ្ញាធរមូលដ្ឋាន ។ អនុសមាសធាតុចុងក្រោយនៅក្នុងសុខភាពមនុស្ស ផ្តល់នូវការគាំទ្រចាំបាច់សំរាប់ការអនុវត្តន៏ទូទៅនូវសមាសធាតុនេះ ដូចជាបុគ្គលិក ចំណាយលើការធ្វើដំណើរមធ្យោបាយដឹកជញ្ជូនចំណាយប្រតិបត្តិនិងតំហែទាំ និងសំភារៈដទៃទៀត ។

សមាសធាតុ គ-កិច្ចសហប្រតិបត្តិការអន្តរក្រសួង សំរាប់ការត្រៀមលក្ខណៈទប់ស្កាត់ការរាលដាលជំងឺជាសាកល និងការសម្របសម្រួលគម្រោង （ការចំណាយសរុបប្រហែល ១.៧០លានដុល្លារអាមេរិក）។ ទិសដៅរបស់កិច្ចសហប្រតិបត្តិការអន្តរក្រសួងសំរាប់សមាសធាតុត្រៀមលក្ខណៈទប់ទល់នឹងការរាលដាលជំងឺជាសាកល គឺត្រូវធ្វើការពង្រឹងសមត្ថភាពរបស់កម្ពុជា ដើម្បីធ្វើការគៀងគរបានឆាប់រហ័ស និងមានប្រសិទ្ធភាព នូវការឆ្លើយតបដែលមានការសំរបសំរួលពហុវិស័យទូទាំងសង្គម ចំពោះការឆ្លងរាលដាលជាសាកលនៃជម្ងឺផ្តាសាយនេះ ។ ការពង្រឹងនូវសមត្ថភាពឆ្លើយតបដែលមានការសំរបសំរួលចំពោះការឆ្លងរាលដាលជាសាកលនៃជម្ងឺផ្តាសាយ ក៏នឹងជួយកែលំអផងដែរនូវប្រសិទ្ធភាពនៃការឆ្លើយតបរបស់កម្ពុជាទៅនឹងទឹកជំនន់ ការរាំងស្ងួត និងគ្រោះមហន្តរាយធម្មជាតិដទៃទៀត ។ ទិសដៅនេះ អាចសម្រេចបានតាមរយៈអនុសមាសធាតុចំនួន ៥ ។ ទី ១ គឺ ភារកិច្ចទទួលខុសត្រូវរួមបច្ចុប្បន្នរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានកែសំរួល ដើម្បីដាក់បញ្ចូលនូវកិច្ចសហប្រតិបត្តិការអន្តរក្រសួង ឬការត្រៀមលក្ខណៈទប់ទល់នឹងការរាលដាលជាសាកលនៃជំងឺផ្តាសាយ និងសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងការមើលខុសត្រូវលើកិច្ចសហប្រតិបត្តិការនេះ នឹងត្រូវបានពង្រឹងតាមរយៈការបណ្តុះបណ្តាលបំពាក់បុគ្គលិក និងវិធានការដទៃទៀត ។ ទី ២ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងត្រូវធ្វើការរៀបចំ និងសាកល្បងនូវ

កម្មវិធីត្រៀមលក្ខណៈ ឆ្លើយតប និងស្តារឡើងពីការរាលដាលជំងឺជាសាកល ។ ទី ៣ ប្រព័ន្ធពត៌មានគ្រប់គ្រង គ្រោះអាសន្ន និងប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតំលៃរបស់គណៈកម្មាធិការជាតិរគ្រប់គ្រងគ្រោះមហន្តរាយ (សំរាប់កម្មវិធីជាតិរួមស្តីអំពីការត្រៀមលក្ខណៈ ការឆ្លើយតប និងការស្តារឡើងពីការរាលដាលជំងឺជាសាកល) នឹងត្រូវបានរៀបចំ និងអភិវឌ្ឍ និងបង្កើតឡើង ។ ទី ៤ សកម្មភាពត្រៀមលក្ខណៈឆ្លើយតបនិងស្តារឡើងពីការរាលដាលជំងឺជាសាកល នឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍ដែលកំពុងដំណើរការ ។ ទីបញ្ចប់ អនុសមាសធាតុទ ៥ នឹងផ្តល់នូវការគាំទ្រ ដល់ការអនុវត្តន៍ទូទៅនៃសមាសធាតុនេះ ។ ដោយសារតែគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងទទួលខុសត្រូវជារួម លើការត្រួតពិនិត្យ និងការសំរបសំរួលនូវរចនាសម្ព័ន្ធស្ថាប័ន និងរចនាសម្ព័ន្ធអនុវត្តន៍សំរាប់គម្រោងទាំងមូលនោះ (រួមទាំងការសំរបសំរួលគម្រោងរួម ការធានានូវការផ្សារភ្ជាប់គ្នារវាងទីភ្នាក់ងារពាក់ព័ន្ធ និងដៃគូអន្តរជាតិ ការណែនាំផ្លូវ និងការពិនិត្យតាមដានការ អនុវត្តន៍គម្រោងនៅថ្នាក់កណ្តាល) អនុសមាសធាតុទី ៥ ក៏នឹងផ្តល់ផងដែរនូវការគាំទ្រដល់មុខងារសំរបសំរួលដ៏សំខាន់នេះ ។

## ៥. ការធ្វើហិរញ្ញប្បទាន

| | |
|---|---|
| ប្រភព: | ($ម) |
| ជំនួយឥតសំណង IDA | ៦.0 |
| ជប៉ុនៈ ក្រសួងហិរញ្ញវត្ថុ- ជំនួយឥតសំណង PHRD | ៣.0 |
| ជំនួយឥតសំណងសំរាប់ជម្ងឺផ្តាសាយបក្សី និងមនុស្ស | ២.0 |
| ចំនួនសរុប | ១១.0 |

## ៦. ការអនុវត្តន៍

### *រចនាសម្ព័ន្ធដៃគូ*

រចនាសម្ព័ន្ធដៃគូដែលមានប្រសិទ្ធភាព និងសមស្របសំរាប់គម្រោងនេះ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាជាមួយនឹងទីភ្នាក់ងារបច្ចេកទេសអន្តរជាតិ ក៏ដូចជាទីភ្នាក់ងារផ្តល់ជំនួយទ្វេភាគី ដែលកំពុងផ្តល់ជំនួយដល់ប្រទេសនេះដោយផ្អែកទៅលើរចនាសម្ព័ន្ធសហប្រតិបត្តិការប្រកបដោយផ្លែផ្កា ដែលត្រូវបានអភិវឌ្ឍន៍ឡើងនៅក្នុងវិស័យកសិកម្ម និងវិស័យសុខាភិបាលស្របនៅក្នុងគម្រោងមុនៗ ។ នៅក្នុងអំឡុងពេលនៃការរៀបចំ និងការវាយតំលៃគម្រោង ការពិគ្រោះយោបល់ជិតស្និទ្ធ ជាមួយបុគ្គលិកក្នុងស្រុករបស់ម្ចាស់ជំនួយពហុភាគី និងទ្វេភាគីដែលមានតំណាងនៅក្នុងប្រទេសកម្ពុជា ត្រូវបានបន្តធ្វើឡើងជាពិសេសជាមួយទីភ្នាក់ងារដែលបានពាក់ព័ន្ធនៅក្នុងឧបត្ថម្ភការគាំទ្រដល់ការអនុវត្តន៍ផែនការជាតិ (ឧទាហរណ៏: អង្គការ UNDP, អង្គការ FAO, អង្គការ WHO, អង្គការ UNICEF, សហគមន៍អ៊ឺរ៉ុប, អង្គការ AFD, USAID, AusAID) ។ ការប្រជុំតុមូលត្រូវបានរៀបចំឡើងនៅមុនពេល និងក្នុងអំឡុងពេលបេសកកម្មវាយតំលៃ ដើម្បីផ្តល់ពត៌មានដល់ដៃគូទាំងនេះ អំពីកម្មវិធីដែលបានគ្រោងទុកសំរាប់ធ្វើការជាមួយរាជរដ្ឋាភិបាល ដើម្បីធ្វើការពង្រឹងនូវផែនការរួមរបស់ជាតិ និងដើម្បីបញ្ជាក់អំពីការចាប់អារម្មណ៏របស់គេនៅក្នុងការផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុនិង/ឬផ្នែកបច្ចេកទេសសំរាប់គម្រោង ក៏ដូចជា ការសម្របសម្រួលនូវសកម្មភាពដែលនឹងត្រូវបានគាំទ្រដោយទីភ្នាក់ងារនីមួយៗ ដើម្បីលើកកំពស់នូវប្រសិទ្ធភាពទូទៅនៃសកម្មភាព និងកម្មវិធីរួម ។

រដ្ឋាភិបាលរបស់ប្រទេសជប៉ុនបានអនុម័តរួចហើយនូវជំនួយហិរញ្ញវត្ថុ (ជំនួយឥតសំណង PHRD) ដែលមានទឹកប្រាក់ចំនួន ៣ លានដុល្លារអាមេរិក សំរាប់គម្រោងនេះ ។ ប្រទេសផ្តល់ជំនួយធំៗមួយចំនួន (ដូចជា អង្គការ UNDP, FAO, WHO, UNICEF, GTZ, JICA, USAID និង AusAID) បានអនុម័តរួចហើយ ឬមានគម្រោងអនុម័ត នៅក្នុងពេលខ្លីខាងមុខនេះ នូវគម្រោងជំនួយបច្ចេកទេស ដើម្បីបំពេញបន្ថែម និងចាប់ផ្តើមអនុវត្តនូវសកម្មភាព ដែលត្រូវបានស្នើឡើងនៅក្នុងផែនការជាតិ ដែលសមស្របជាមួយនឹងគម្រោងដែលត្រូវបានស្នើឡើងនេះ ។ មូលនិធិ Trust Fund របស់ម្ចាស់ជំនួយច្រើន - មូលនិធិសំរាប់ជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស (AHI Facility) - ត្រូវបានបង្កើតឡើង ដើម្បីផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុទៅដល់ប្រទេសនីមួយៗក្នុងការត្រៀមលក្ខណៈទៅនឹងការរាលដាលជំងឺជាសាកលនៅក្នុងចំណោមមនុស្ស ។ មូលនិធិនេះ ត្រូវបានគ្រប់គ្រងដោយធនាគារពិភពលោក ហើយទឹកប្រាក់ចំនួនទឹកប្រាក់សរុបចំនួន ២លានដុល្លារអាមេរិក ត្រូវបានអនុម័តដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងដែលត្រូវបានស្នើរឡើងនេះ ។

## *រចនាសម្ព័ន្ធស្ថាប័ន និងរចនាសម្ព័ន្ធអនុវត្តន៍*

ទីភ្នាក់ងារអនុវត្តន៍: រាជរដ្ឋាភិបាលបានធ្វើការសំរេចថាការអនុវត្តន៍គម្រោង គឺជាការទទួលខុសត្រូវរបស់ភ្នាក់ងារអនុវត្តន៍ ចំនួន ៣ ខាងក្រោម:

ក) សមាសធាតុ ក: សមាសធាតុសុខភាពសត្វ នឹងត្រូវបានអនុវត្តដោយនាយកដ្ឋានសុខភាព និងផលិតផលសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរចនាសម្ព័ន្ធដែលមានស្រាប់របស់ខ្លួន និងដោយមានការគាំទ្រពីអង្គភាពដែលទទួលខុសត្រូវលើមុខងារសម្របសម្រួលសំរាប់សមាសធាតុនេះ។ អង្គភាពនេះ នឹងត្រូវបានបំពាក់បុគ្គលិកដោយអ្នកឯកទេសផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ផ្នែកលទ្ធកម្ម និងផ្នែកពិនិត្យតាមដាន និងវាយតំលៃ ព្រមទាំងទីប្រឹក្សាបច្ចេកទេសពីខាងក្រៅ ។ គេបានរំពឹងថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មមួយជាមួយអង្គការ FAO ដែលនៅក្នុងកិច្ចព្រមព្រៀងនេះ ទីភ្នាក់ងារអន្តរជាតិមួយនេះនឹងផ្តល់នូវ (i) ការពង្រឹងស្ថាប័នដែលចាំបាច់សំរាប់ការអនុវត្តន៍នូវសមាសធាតុនេះ និង (ii) ជំនួយបច្ចេកទេសនៅក្នុងផ្នែកសំខាន់ៗ បទពិសោធន៍អន្តរជាតិរបស់ខ្លួននៅក្នុងផ្នែកសុខភាពសត្វជាទូទៅ ក៏ដូចជាបទពិសោធន៍នៅក្នុងកិច្ចប្រឹងប្រែងទូទាំងពិភពលោក ដែលនឹងត្រូវបានអនុវត្តដើម្បីធ្វើការទប់ស្កាត់នូវភាពឆ្លងរាលដាលនៃជម្ងឺគ្រុនផ្តាសាយបក្សី ។ អង្គការ FAO ត្រូវបានទទួលស្គាល់ថា ជាទីភ្នាក់ងារមួយនៅក្នុងចំណោមទីភ្នាក់ការងបច្ចេទេសនាំមុខគេក្នុងការអនុវត្តន៍ យុទ្ធសាស្ត្រសុខភាពសត្វ ដើម្បីបញ្ឈប់ភាពឆ្លងរាលដាលនៃជម្ងឺគ្រុនផ្តាសាយ H5N1 ។

ខ) **សមាសធាតុ ខ:** សមាសធាតុសុខភាពមនុស្ស នឹងត្រូវបានអនុវត្តដោយក្រសួងសុខាភិបាល តាមរយៈ អង្គភាព PIU ដែលមានស្រាប់ ដែលទទួលខុសត្រូវលើគម្រោងគាំទ្រវិស័យសុខាភិបាលដែលកំពុងមានដំណើរការ ។ អង្គភាព PIU នេះមានធនធានមនុស្ស និងមានជំនាញគ្រប់គ្រាន់រួចជាស្រេច ក្នុងការទទួលយកនូវការទទួលខុសត្រូវថ្មីៗទាំងនេះ ។ ប៉ុន្តែ ទីប្រឹក្សាមួយចំនួនបន្ថែមទៀត នឹងត្រូវបានជួលមកធ្វើការពង្រឹងសមត្ថភាពស្ថាប័នរបស់អង្គភាព នៅក្នុងការអនុវត្តន៍សមាសធាតុនេះ (ការគ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យ និងរដ្ឋបាល) ។ ក្រៅពីនេះ គេបានរំពឹងថាក្រសួងសុខាភិបាល នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្ម ជាមួយអង្គការសុខភាពពិភពលោក ដើម្បីទទួល

បាននូវជំនួយបច្ចេកទេស និងការកសាងសមត្ថភាព នៅក្នុងការអនុវត្តន៍សមាសធាតុនេះ ។ អង្គការសុខភាពពិភពលោក ត្រូវបានគេទទួលស្គាល់ជាអន្តរជាតិថាជាទីភ្នាក់ងារឯកទេសរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ដែលកំពុងគាំទ្រដល់ការឆ្លើយតបទៅនឹងការគំរាមគំហែងនៃជម្ងឺគ្រុនផ្តាសាយបក្សី នៅក្នុងប្រទេសជាច្រើនជុំវិញពិភពលោក ហើយនឹងទទួលខុសត្រូវលើការគាំទ្រដល់ផ្នែកសំខាន់ៗនៃផែនការរួមរបស់ជាតិនៅក្នុងប្រទេសកម្ពុជា ។

គ) សមាសធាតុ គ: តាមរយ:អគ្គលេខាធិការដ្ឋានរបស់ខ្លួន គណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងទទួលខុសត្រូវលើការសម្របសម្រួលអន្តរក្រសួង សំរាប់ការត្រៀមលក្ខណ:ទៅនឹងការរាលដាលជំងឺជាសាកល ក៏ដូចជាការទទួលខុសត្រូវទៅលើការសម្របសម្រួល និងការគ្រប់គ្រងទូទៅនៃគម្រោងនេះ។ បុគ្គលិកបច្ចុប្បន្នរបស់អគ្គលេខាធិការដ្ឋាន នឹងត្រូវបានពង្រឹងដោយការជួលទីប្រឹក្សាឱ្យមកធ្វើការនៅក្នុងផ្នែកសំខាន់ៗ ជាពិសេសនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ធនធានមនុស្ស និងការពិនិត្យតាមដាន និងការវាយតំលៃ ។ ស្រដៀងគ្នាទៅនឹងសមាសធាតុដទៃទៀត គេបានរំពឹងថា គណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្ម ជាមួយអង្គការ UNDP ដើម្បីទទួលបាននូវជំនួយបច្ចេកទេសនៅក្នុងអំឡុងពេលអនុវត្តន៍ ។ កិច្ចព្រមព្រៀងសេវាកម្មនេះ នឹងពង្រីក និងបំពេញបន្ថែមទៅលើកម្មវិធីកសាងសមត្ថភាពបច្ចុបន្ន ដែលត្រូវបានគាំទ្រដោយទីភ្នាក់ងារដទៃទៀតនៃប្រព័ន្ធអង្គការសហប្រជាជាតិ ។

នៅក្នុងវិធីសាស្ត្រការអនុវត្តន៍នេះ រាជរដ្ឋាភិបាលកម្ពុជា (ក្នុងនាមជាអ្នកទទួលជំនួយហិរញ្ញប្បទាន) នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទាន ជាមួយធនាគារ ឬមូលនិធិ IDA ក៏ដូចជា ក្នុងកិច្ចព្រមព្រៀងជំនួយ សំរាប់ទទួលបានជំនួយពី PHRD និងមូលនិធិសំរាប់ជម្ងឺផ្តាសាយបក្សី និងមនុស្ស ។ រចនាសម្ព័ន្ធស្ថាប័ន និងរចនាសម្ព័ន្ធ អនុវត្តន៍ និងចូលរួមចំណែកអោយមាននូវការអនុវត្តន៍ឆាប់រហ័ស និងមានប្រសិទ្ធភាពចំណាយ ផ្តល់ការធានាអះអាងថា ប្រព័ន្ធឃ្លាំមើលនិងឆ្លើយតបមានដំណើរការពេញលេញនៅក្នុងរយ:ពេលខ្លី ដែលអាចផ្តល់នូវការឆ្លើយតបដ៏មានប្រសិទ្ធភាព នៅក្នុងពេលមានការរាតត្បាតនៅក្នុងចំណោមបសុបក្សី ឬមនុស្សជាច្រើនករណី ។ សំរាប់ការអនុវត្តន៍សកម្មភាពទាំងនេះ មូលនិធិពីប្រភពបី (IDA, PHRD និងមូលនិធិសំរាប់ជម្ងឺគ្រុនផ្តាសាយបក្សី និងមនុស្ស) នឹងបានធ្វើបុរេប្រទាន ដោយធនាគារពិភពលោកដោយផ្ទាល់ចូលទៅក្នុងគណនីជាក់លាក់ដែលត្រូវបានបើកដោយភ្នាក់ងារអនុវត្តន៍នីមួយៗ(គណនេយ្យ មួយសំរាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងពីរសំរាប់ក្រសួងសុខាភិបាល និងគណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ) ក្នុងលក្ខណ:ដែលអាចទទួលយកបានដោយ IDA ។

ភ្នាក់ងារអនុវត្តន៍នីមួយៗ នឹងត្រូវរៀបចំ និងដាក់ជូនគណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលជាភ្នាក់ងារទទួលខុសត្រូវលើការសម្របសម្រួលទូទៅ: (i) ផែនការអនុវត្តន៍គម្រោងសំរាប់សកម្មភាពគទាំងអស់របស់គម្រោង ដែលបានដាក់បញ្ចូលនៅក្នុងសមាសធាតុរបស់ខ្លួន (ii) ផែនការការងារប្រចាំឆ្នាំ (រួមទាំងថវិកា) សំរាប់ឆ្នាំទីមួយៗ (iii) របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុសំរាប់ឆ្នាំកន្លងទៅ (iv) របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នសំរាប់ត្រីមាសនីមួយៗ ។ ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន សំរាប់ត្រីមាសទីបួននោះ គណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសំរាប់គម្រោងទាំងមូល ដែលត្រូវបានធ្វើសវនកម្ម ដោយសវនករ ឯករាជ្យ ដែលមានភារកិច្ចទទួលខុសត្រូវរួម ដែលអាចទទួលយកបានដោយ IDA ។

បន្ថែមពីលើការទទួលខុសត្រូវរបស់ខ្លួនក្នុងនាមជាភ្នាក់ងារអនុវត្តន៏សំរាប់សមាសធាតុ គ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងទទួលខុសត្រូវលើការសម្របសម្រួល និងការគ្រប់គ្រងគម្រោងទាំងមូល ដោយធានាអោយមានផ្សារភ្ជាប់គ្នារវាងទីភ្នាក់ងារដែលពាក់ព័ន្ធជាមួយដៃគូអន្តរជាតិ និងទទួលខុសត្រូវលើការណែនាំ និងការពិនិត្យតាមដាននូវការអនុវត្តន៏គម្រោងនៅថ្នាក់កណ្តាល ក៏ដូចជាការបំពេញនូវតួជាសមភាគីដ៏សំខាន់សំរាប់ IDA ។ សំរាប់គោលបំណងនេះ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងត្រូវពឹងផ្អែកទៅលើរចនាសម្ព័ន្ធដែលមានស្រាប់របស់ខ្លួន ដោយប្រើប្រាស់នូវអគ្គលេខាធិការដ្ឋានរបស់ខ្លួនជា អង្គភាពទទួលខុសត្រូវដ៏សំខាន់ និងដែលមានអគ្គលេខាធិការ និងអគ្គលេខាធិការរងរបស់ខ្លួន ធ្វើជានាយកគម្រោង និងអ្នកគ្រប់គ្រងគម្រោង ។ ដើម្បីបំពេញនូវមុខងារទាំងនេះ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងធ្វើជ្រើសរើសទីប្រឹក្សាអោយមកជួយពង្រឹងសមត្ថភាពរបស់ខ្លួនជាពិសេសនៅក្នុងផ្នែករដ្ឋបាលទូទៅ ការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ការពិនិត្យតាមដាន និងការវាយតំលៃការបណ្តុះបណ្តាល និងធនធានមនុស្ស ។ កិច្ចព្រមព្រៀងសេវាកម្ម ដែលនឹងត្រូវបានចុះហត្ថលេខារដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការ UNDP ក៏នឹងចូលរួមចំណែកផងដែរ ដល់ការពង្រឹងផ្នែកស្ថាប័នរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីបំពេញនូវមុខងារនេះ ។

## ***ការពិនិត្យតាមដាន និងការវាយតំលៃលទ្ធផល***

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងទទួលខុសត្រូវទៅលើការបង្កើត និងថែទាំប្រព័ន្ធពិនិត្យតាមដាន និងវាយតំលៃសំរាប់គម្រោងទាំងមូល ។ នៅក្នុងក្របខណ្ឌរួមនេះ ភ្នាក់ងារអនុវត្តន៏នីមួយៗ នឹងទទួលខុសត្រូវទៅលើការបង្កើត និងប្រតិបត្តិការនៃប្រព័ន្ធពិនិត្យតាមដាន និងវាយតំលៃសំរាប់សមាសធាតុគម្រោងរៀងៗខ្លួនរបស់ពួកគេ ។ អាស្រ័យទៅលើស្ថានភាពជាក់លាក់នៅក្នុងករណីនីមួយៗ សកម្មភាពទាំងអស់នេះ អាចនឹងត្រូវបានអនុវត្តដោយបុគ្គលិក របស់ភ្នាក់ងារអនុវត្តន (ដោយមានការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដែលត្រូវបានផ្តល់ឱ្យដោយគម្រោងនេះ) ឬដោយទីភ្នាក់ងារឯកទេសឬវិទ្យាស្ថានឯកទេសដែលបានចុះកិច្ចសន្យានៅក្នុងគម្រោងនេះ ។ នៅក្នុងករណីសមាសធាតុសុខភាពសត្វ ការពិនិត្យតាមដាន និងការវាយតំលៃ នឹងត្រូវបានគាំទ្រដោយការតែងតាំងអ្នកគ្រប់គ្រងគម្រោងប្រចាំតំបន់ដែល នឹងធ្វើការពិនិត្យតាមដានយ៉ាងទៀងទាត់នូវសកម្មភាពគម្រោង ដោយមានមន្ត្រីពិនិត្យតាមដាន និងវាយតំលៃថ្នាក់កណ្តាល នៅក្នុងក្រុមគ្រប់គ្រងគម្រោងនៃសមាសធាតុសុខភាពសត្វ ។

ការពិនិត្យតាមដានវឌ្ឍនភាព នៅក្នុងការអនុវត្តន៏ និងនៅក្នុងការឈានទៅរកការសម្រេចបាននូវទិសដៅដែលបានគ្រោងទុក ទាមទារអោយមាននូវដំណើរការពិនិត្យឡើងវិញជាប្រចាំ និងសមស្របទៅលើកម្មភាពផ្សេងៗគ្នានៃគម្រោង ។ សកម្មភាពពិនិត្យតាមដាន និងវាយតំលៃមានគោលបំណង: (i) ធ្វើការវាស់វែងនូវសូចនាករអំពីទិន្នន័យបញ្ចូលលទ្ធផលផ្ទាល់ និងលទ្ធផលប្រយោល (ii) ផ្តល់ពត៌មានទៀងទាត់ និងស្របតាមពេលវេលាអំពីវឌ្ឍនភាពឈានទៅរកការសំរេចបាននូវលទ្ធផលដែលបានគ្រោងទុក និងជួលសម្រួលដល់ការធ្វើរបាយការណ៏ជូនដល់រដ្ឋាភិបាល និង IDA (iii) ជូនដំណឹងដល់អាជ្ញាធររដ្ឋាភិបាល និងធនាគារអំពីបញ្ហាជាក់ស្តែង ឬបញ្ហាដែលអាចនឹងកើតមានឡើងនៅក្នុងការអនុវត្តន៏ ដើម្បីធ្វើការកែតំរូវបាន និង (iv) ដើម្បីធ្វើការសំរេចថាតើស្ថាប័នពាក់ព័ន្ធធ្វើការឆ្លើយតប ដូចដែលបានរំពឹងទុក និងគ្រោងទុកដែរឬទេ ។

របកគំហើញដែលទទួលបានពីសកម្មភាពពិនិត្យតាមដាន និងវាយតំលៃដែលពាក់ព័ន្ធ នឹងត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៏វឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ របាយការណ៏វឌ្ឍនភាពនេះ នឹងគ្របដណ្តប់ទៅលើការអនុវត្តន៏សកម្មភាពដែលបានទាក់ទងនឹងកិច្ចការស៊ីវិល សកម្មភាពស្ថាប័ន ការបណ្តុះបណ្តាល និងការសិក្សា សូចនាករអនុវត្តន៏ និងរបាយការណ៏ហិរញ្ញវត្ថុ

បណ្ដោះអាសន្ន ។ របាយការណ៍ទាំងនេះ ក៏នឹងរួមបញ្ចូលផងដែរនូវបញ្ហា ដែលត្រូវបានរកឃើញនៅក្នុងពេលអនុវត្តន៍ និងយុទ្ធសាស្ត្រ និងវិធានការ ដែលបានស្នើរឡើងដើម្បីដោះស្រាយនូវបញ្ហាផ្សេងៗ ដែលប៉ះពាល់ដល់វឌ្ឍនភាពរបស់គំរោង ។ របាយការណ៍ប្រចាំត្រីមាសទី ៤ ក្នុងឆ្នាំនីមួយៗ គឺជារបាយការណ៍ប្រចាំឆ្នាំ ដែលរួមបញ្ចូលនូវវឌ្ឍនភាព នៅក្នុងអំឡុងឆ្នាំកន្លងទៅ ។ ក្រៅពីនេះ របាយការណ៍វឌ្ឍនភាពពាក់កណ្ដាលអាណត្តិ នឹងត្រូវបានធ្វើឡើង នាពាក់កណ្ដាលនៃការអនុវត្តន៍ និងក្លាយទៅជាទិន្នន័យបញ្ចូលសំរាប់ការវាយតំលៃពាក់កណ្ដាលអាណត្តិ ដែលនឹងផ្ដល់នូវឱកាសសំរាប់ការពិនិត្យឡើងវិញរួមគ្នា (រាជរដ្ឋាភិបាល អ្នកអនុវត្តន៍ ដៃគូនិងម្ចាស់ជំនួយ/ហិរញ្ញិក) នូវបទពិសោធន៍ និងមេរៀនដែលទទួលបាន និងធ្វើការពិភាក្សាអំពីការកែតសំរួលនូវប្លង់ កាលវិភាគអនុវត្តន៍ និងលទ្ធផលផ្ទាល់/លទ្ធផលប្រយោល ដែលត្រូវបានរំពឹងទុកប្រសិនបើចាំបាច់ ។ របាយការណ៍បញ្ចប់ការអនុវត្តន៍ នឹងត្រូវបានរៀបចំឡើងដោយភ្នាក់ងារអនុវត្តន៍ និងធនាគារពិភពលោក នៅក្នុងរង្វង់រយៈពេល ៦ខែ ចាប់ពីថៃបញ្ចប់នូវការឧបត្ថម្ភគាំទ្រ ។

## ៧. និរន្តរភាព

ភាពជាម្ចាស់ដែលស្ថិតមាននៅជាបន្តទៅលើការផ្ដួចផ្ដើមនេះ ដោយអ្នកដែលពាក់ព័ន្ធ រួមគ្នាជាមួយនឹងការគាំទ្ររឹងមាំផ្នែកនយោបាយ និងការមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីអនុវត្តន៍សកម្មភាពគម្រោងមានសារៈសំខាន់ខ្លាំងណាស់ចំពោះនិរន្តរភាពរបស់គំរោង ។ និរន្តរភាពស្ថាប័ននឹងត្រូវបានធានាដោយៈ (i) ការពង្រឹងកម្មវិធី ដើម្បីថែរក្សានូវយល់ដឹងរបស់សាធារណៈជនអំពីការគំរាមគំហែងពីជម្ងឺគ្រុនផ្ដាសាយបក្សីដែលមានអត្រាឆ្លងខ្ពស់ និងជម្ងឺឆ្លងរាលដាលយ៉ាងឆាប់រហ័សដទៃទៀត (ii) សកម្មភាពការឃ្លាំមើលបង្ការ និងការទប់ស្កាត់ប្រកបដោយចីរភាព ជាពិសេសនៅក្នុងតំបន់មានគ្រោះថ្នាក់ខ្ពស់ (iii) សមត្ថភាប្រទេសដែលត្រូវបានពង្រឹងដើម្បីគ្រប់គ្រងនូវកត្តាគ្រោះថ្នាក់ដែលពាក់ព័ន្ធទៅនឹងការរាលដាលនៃជម្ងឺគ្រុនផ្ដាសាយបក្សីដែលមានអត្រាឆ្លងខ្ពស់ និងជំងឺឆ្លងដទៃទៀត នៅក្នុងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និង (iv) ប្រសិទ្ធភាពនៃកម្មវិធីក្នុងការទប់ស្កាត់នូវការរាលដាលនៃជម្ងឺគ្រុនផ្ដាសាយបក្សី ដែលមាន អត្រាឆ្លងខ្ពស់ ពីក្នុងចំណោមសត្វបក្សី ទៅក្នុងចំណោមមនុស្សទូទៅ ។

## ៨. មេរៀនដែលទទួលបានពីប្រតិបត្តិការនាពេលអតីតកាលនៅក្នុងប្រទេស/វិស័យ

គម្រោងកន្លងទៅស្ដីអំពីស្ដារឡើងវិញក្រោយពេលមានគ្រោះអាសន្ន ដែលបានគាំទ្រដោយធនាគារពិភពលោក/IDA បានផ្ដល់នូវមេរៀនសមស្របជាច្រើនសំរាប់ការរៀបចំគម្រោង ។ មេរៀនដែលទទួលបាន ស្ដីអំពីភាពសមស្របជាក់លាក់សំរាប់គម្រោងជម្ងឺគ្រុនផ្ដាសាយបក្សី និងមនុស្សនោះ រួមមានៈ (a) គម្រោងគ្រោះអាសន្ន ត្រូវជៀសវាងនូវល័ក្ខខ័ណ្ឌគោលនយោបាយ (b) ប្លង់នៃគម្រោង ត្រូវតែមានលក្ខណៈងាយស្រួល និងរួមបញ្ចូលនូវ ការវាយតំលៃជាក់ស្ដែងអំពីសមត្ថភាពរបស់អ្នកខ្ចី និងសមត្ថភាពរបស់អ្នកដែលពាក់ព័ន្ធដទៃទៀត (c) ការវាយតំលៃបន្ទាន់ និងការអនុម័តិយ៉ាងឆាប់រហ័ស មានសារៈសំខាន់ខ្លាំងណាស់ដើម្បីផ្ដល់នូវការឆ្លើយតបទាន់ពេលវេលា និងការចូលរួមចំណែកដដំ ដល់ភាពជោគជ័យរបស់គម្រោង (d) រចនាសម្ព័ន្ធចំលទ្ធកម្មត្រូវមានលក្ខណៈបត់បែន និងគួរតែត្រូវបានសំរេចរួចរាល់នៅក្នុងដំណាក់កាលដំបូង ហើយ (e) ការវាយតំលៃជាក់ស្ដែងគួរត្រូវបានធ្វើឡើងទៅលើ សមត្ថភាពស្រូបទាញរបស់សមភាគី ក៏ដូចជាយន្តការប្រាស្រ័យទាក់ទង និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាព នៅក្នុងចំណោម នៅក្នុងចំណោមអ្នកដែលពាក់ព័ន្ធទាំងអស់ ។

បទពិសោធន៍ ដែលទទួលបានតាមរយៈការអនុវត្តន៍គម្រោងគ្រោះអាសន្នដទៃទៀត ផ្តល់នូវមេរៀនដ៏សំខាន់ បន្ថែមទៀត ។ គម្រោងទាំងនេះ រួមមាន គម្រោងសស្តារឡើងវិញពីគ្រោះអាសន្នជម្ងឺគ្រុនផ្តាសាយនៅវៀតណាម គម្រោងឆ្លើយតបទៅ នឹងការរាតត្បាតនៃជម្ងឺ Sars និងគម្រោងឆ្លើយតបនឹងការឆ្លងរាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ ។ មេរៀនបន្ថែមសំខាន់ៗ ដែលទទួលបាន រួមមានៈ

- ការរៀបចំនូវយុទ្ធសាស្រ្តជាតិដែលមានគុណភាពល្អ គឺជាកត្តាដ៏សំខាន់ ។
- នៅក្នុងការអនុវត្តន៍ ប្រការដ៏មានសារៈសំខាន់នោះ គឺថាគេត្រូវមានរចនាសម្ព័ន្ធសំរបសំរួល ដែលមានការទទួលខុសត្រូវពហុវិស័យ ជាឧទាហរណ៍ នៅក្នុងថ្នាក់ខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី និងត្រូវមានអ្នកសម្របសម្រួលគម្រោងពេញម៉ោង ដើម្បីអនុវត្តន៍សកម្មភាពនៅក្នុងពេលមាន "ស្ថានភាពវិបត្តិ " ។
- ការពង្រឹងសមត្ថភាពបច្ចេទេស សមត្ថភាពវិទ្យាសាស្រ្ត និងសមត្ថភាពប្រតិបត្តិការរបស់ភ្នាក់ងារដែលពាក់ព័ន្ធមានសារៈសំខាន់ខ្លាំងណាស់ ។
- ប្រការដ៏មានសារៈសំខាន់នោះ គឺថាគេត្រូវធ្វើការលើកកំពស់ការយល់ដឹងនៅក្នុងផ្នែករដ្ឋ និងផ្នែកឯកជនអោយបានឆាប់រហ័សទាន់ពេលវេលាតាមដែលអាចធ្វើទៅបាន ហើយគេត្រូវពង្រឹងយន្តការសំរបសំរួលដែលមានប្រសិទ្ធភាពសំរាប់ការអនុវត្តន៍នូវការឆ្លើយតបផ្នែកបច្ចេកទេសចាំបាច់ អោយមានការចូលរួមពីសំណាក់រដ្ឋាភិបាល សហគមន៍ផ្តល់ជំនួយ ឯកជន និងសង្គមស៊ីវិល ។
- ការឃ្លាំមើលថ្នាក់ជាតិដែលមានគុណភាពល្អ គឺមានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងបង្ការនូវរាលដាលនៃជំងឺ ។
- គេត្រូវការនូវការសន្យាផ្នែកនយោបាយ និងពីសំណាក់ថ្នាក់ដឹកនាំជាន់ខ្ពស់ ។
- វិធីសាស្រ្តពហុវិស័យពេញលេញក្នុងផ្តល់សេវាការបង្ការ ការព្យាបាល ថែទាំ និងគាំទ្រ ផ្តល់នូវលទ្ធភាពប្រសើរបំផុតសំរាប់ការសំរេចបាននូវភាពជោគជ័យ ។ នៅក្នុងពេលដែលគេនៅតែត្រូវតែផ្តោតការយកចិត្តទុកដាក់ទៅលើការបង្ការ ដែលជាមធ្យោបាយមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងគំរាមគំហែងរបស់ជម្ងឺគ្រុនផ្តាសាយបក្សីនោះ កម្មវិធីក៏ត្រូវស្វះស្វែងផងដែរធ្វើការដោះស្រាយនូវបញ្ហាទាំងអស់ ដែលពាក់ព័ន្ធទៅនឹងសេវាបង្ការព្យាបាល ថែទាំ និងសេវាគ្រាំទ្រ ។

## ៩. គោលនយោបាយរក្សាសុវត្ថិភាព (រួមទាំងការពិគ្រោះយោបល់សាធារណៈ)

| គោលនយោបាយរក្សាសុវត្ថិភាព ដែលបង្កើតឡើងដោយគម្រោង | បាទ | ទេ |
|---|---|---|
| ការវាយតំលៃបរិស្ថាន(OP/BP 4.01) | [ X ] | [ ] |
| លំនៅដ្ឋានធម្មជាតិ (OP/BP 4.04) | [ ] | [ X ] |
| ការគ្រប់គ្រងសត្វចង្រៃ (OP/BP 4.09) | [ ] | [ X ] |
| ទ្រព្យសម្បត្តិវប្បធម៌ (OPN 11.03) ត្រូវបានកែសំរួលជា OP 4.11) | [ ] | [ X ] |
| ការតាំងទីលំនៅដោយមិនស័គ្រចិត្ត (OP/BP 4.12) | [ ] | [ X ] |
| អ្នកស្រុកដើម (OP/BP 4.10) | [ X ] | [ ] |

| | | |
|---|---|---|
| ព្រៃឈើ (OP/BP 4.36) | [ ] | [ X ] |
| សុវត្ថិភាពនៃទំនប់ទឹក (OP/BP 4.37) | [ ] | [ X ] |
| គម្រោងនៅក្នុងតំបន់មានជល្លោះ (OP/BP 7.60 )* | [ ] | [ X ] |
| គម្រោងផ្លូវទឹកអន្តរជាតិ (OP/BP 7.50 ) | [ ] | [ X ] |

## ១០. អាសយដ្ឋានទំនាក់ទំនង


សូមទំនាក់ទំនង: Alan Piazza

ងារ: អ្នកសេដ្ឋកិច្ចជាន់ខ្ពស់

ទូរស័ព្ទលេខ: (២០២) ៤៥៨-៤០៦៧

ទូរសារលេខ: (២០២) ៤៧៧-២៧៣៣

សារអេឡិចត្រូនិក: apiazza@worldbank.org


## ១១. ព័ត៌មានទាក់ទងបន្ថែមទៀត


អ៊ីនហ្វូស្ហប់ Infoshop

ធនាគារពិភពលោក

1818 H Street, NW
Washington, D.C. 20433

ទូរស័ព្ទលេខ: (២០២) ៤៥៨-៤៥០០

ទូរសារលេខ: (២០២) ៥២២-១៥០០

សារអេឡិចត្រូនិក: pic@worldbank.org

គេហទំព័រ: http://www.worldbank.org/infoshop


* ដោយការគាំទ្រដល់គម្រោងដែលបានស្នើឡើងនេះធនាគារគ្មានបំណងធ្វើការវិនិច្ឆ័យដោយលំអៀងទៅលើការទាមទាររបស់ភាគីណាមួយទៅលើតំបន់ដែលមានជម្លោះនោះទេ។